ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១០៤/១៣-សាប្រ៊ីណា (ខេមបូឌា)
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៣

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ហួន ជុនឌី**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន សាប្រ៊ីណា (ខេមបូឌា) ហ្គាម៉ិន ម៉ាញ៉ូហ្វាក់ធឺរីង ខប**

អាសយដ្ឋាន ៖ ផ្លូវជាតិលេខ ៤ ភូមិឬស្សី ឃុំសំបូរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

ទូរស័ព្ទ ៖ ០១២ ២៦៣ ៥២២ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមប្រជុំមុនសវនាការ ៖

១- អ្នកស្រី ហុង លុយ ប្រធានរដ្ឋបាល

២- អ្នកស្រី យូ សុខចាន់ បុគ្គលិករដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា**

អាសយដ្ឋាន ៖ ផ្ទះលេខ ១៦ A ផ្លូវលេខ ៣៦០ សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១៧ ៥៥២ ៤៥២ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតចូលរួមប្រជុំមុនសវនាការ ៖ អវត្តមាន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សុំឱ្យក្រុមហ៊ុនផ្តល់ខែគោល ១៤ ដុល្លារ បន្ថែមតាមប្រកាសរបស់រាជរដ្ឋាភិបាល។

២- សុំឱ្យក្រុមហ៊ុនផ្តល់កម្មករនិយោជិតដែលធ្វើការចាប់ពី ២ ខែ ឡើងទៅ ទទួលបាននៅអត្ថប្រយោជន៍ផ្សេងៗ ដូចកម្មករនិយោជិតដែលជួសឈាមហើយដែរ។

៣- សុំឱ្យក្រុមហ៊ុនផ្តល់អាហារថ្ងៃត្រង់មួយពេល ឬផ្តល់ប្រាក់ ៤០០០ រៀល ក្នុងមួយថ្ងៃរួមទាំងថ្ងៃបុណ្យ និងថ្ងៃអាទិត្យ។

៤- សុំឱ្យក្រុមហ៊ុនផ្តល់កម្មករនិយោជិតដែលធ្វើការថ្ងៃអាទិត្យ និងបន្ថែមម៉ោងពេលយប់ គិតប្រាក់ឈ្នួលគុណនឹង ៣។

៥- សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃបាយបន្ថែមម៉ោង បន្ថែមមួយម៉ោង ១០០០ រៀល។

៦- សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ធ្វើដំណើរ ឬស្នាក់នៅបន្ថែម ៨ ដុល្លារ។

៧- សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ទឹកដោះគោ ២៥ ដុល្លារ ក្នុងមួយខែ រយៈពេល ២០ ខែ។

៨- សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់រង្វាន់ការងារទៀងទាត់បន្ថែម ១០ ដុល្លារ។

៩- សុំឱ្យក្រុមហ៊ុនគោរពតាមកិច្ចព្រមព្រៀងជាមួយសហជីពសេរីកម្មករ កាលថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៣ កន្លងមក។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១២១ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ (អាណត្តិទី១០)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៦២៩/១៣ ក.ប/ក.ស្ក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ។

**កាលបរិច្ឆេទជួបប្រជុំមុនសវនាការ ៖** ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (វេលាម៉ោង ០២ និង ០០ នាទី រសៀល)។

THE ARBITRATION COUNCIL

បញ្ហានៃនីតិវិធី ៖

នៅថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១៣ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ បានទទួលដំណឹងអំពីករណីកម្មករធ្វើកូដកម្មនៅក្នុងក្រុមហ៊ុន សាប្រ៊ីណា (ខេមបូឌា) ដែលដឹកនាំដោយសហជីពសេរីកម្មករប្រចាំក្រុមហ៊ុន។ បន្ទាប់ពីបានទទួលបណ្តឹងនេះ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣ ដោយទទួលបានលទ្ធផលមិនសះជា នឹងគ្នាចំនួន ០៩ ចំណុច លើការទាមទារចំនួន ០៩ ចំណុច។ ចំណុចមិនសះជាចំនួន ០៩ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ តាមរយៈរបាយការណ៍ ស្តីពីការដោះស្រាយវិវាទការងាររួមលេខ ៦២៩/១៣ កប/ក.ស្ព ចុះថ្ងៃ ទី២១ ខែឧសភា ឆ្នាំ២០១៣។

កូដកម្មនៅតែបន្ត បន្ទាប់ពីសំណុំរឿងត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលលិខិតរបស់ក្រុមហ៊ុន សាប្រ៊ីណា (ខេមបូឌា) ហ្គាមិន ម៉ាញូហ្វាក់ធឺរីង ខប ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ ស្តីពីសំណើសុំចេញសេចក្តីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិត ចាប់ពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាលេខ ០២១/១៣ កបអ. ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៣ ឱ្យកូដករផ្អាកជាបន្ទាន់នូវការធ្វើកូដកម្មនៅក្រុមហ៊ុន សាប្រ៊ីណា (ខេមបូឌា) រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាលត្រូវបានចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីព្រឹកថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៣ តទៅតាមវេនរបស់ខ្លួន។ កូដករនៅបន្តធ្វើកូដកម្មដដែល ដោយកូដករមិនបានគោរពតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះទេ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីទាំងពីរមកសាកសួរព័ត៌មានបន្ថែម ក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលនៅថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០១៣ នៅវេលាម៉ោង ០២៖០០ នាទី រសៀល។ ភាគីនិយោជកមានវត្តមានតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ហើយបានអះអាងថា កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម ។ ភាគីកម្មករនិយោជិតមិនមានវត្តមានតាមការអញ្ជើញ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងសម្រេចដូចខាងក្រោម ៖

**តស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

- លិខិតរបស់នាយិកាក្រុមហ៊ុន សាប្រ៊ីណា (ខេមបូឌា) ហ្គាមិន ម៉ាញូហ្វាក់ធើរីន ខប ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ គោរពជូន ប្រធានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំចេញសេចក្តីបញ្ជាឱ្យកម្មករនិយោជិតផ្អាកធ្វើកូដកម្ម។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន**

THE ARBITRATION COUNCIL

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន សាប្រ៊ីណា (ខេមបូឌា) លេខ ៦២៥/១៣ ក.ប/ក.ស្ក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន សាប្រ៊ីណា (ខេមបូឌា) ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- សេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០២១/១៣ កបអ. ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០១៣។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មាន លេខ ៥៣១ កប/អក/វក/លកអ. ចុះថ្ងៃទី២៧ ខែ ឧសភា ឆ្នាំ២០១៣។

៣- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៥៣២ កប/អក/វក/លកអ. ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ ។

**អង្គហេតុ**

- មិនមានការរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជា ដែលមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានដំណើរការសវនាការ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ?

ប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា ៖ "*ក្នុងអំឡុងពេល នៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម* "។

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីវិវាទត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ នៅក្នុងដំណើរការអាជ្ញាកណ្តាល។

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រានេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាភាគីកម្មករនិយោជិត កំពុងធ្វើកូដកម្ម ឬនិយោជកធ្វើឡុកអៅ។

*(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៥៩/០៦-សាង វ៉ លេខ៣៩/០៨-ចុង យ៉ូវ លេខ ១៣៧/០៩ និង ១៣៨/០៩-ញ៉ូ ភាញ៉ូ និង លេខ ១១០/១១- ស៊ីម៉ាណូ)* ។

ឧទាហរណ៍ នៅក្នុងសំណុំរឿងលេខ ០៤/០៤-អិម អេស អាយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីជូនដំណឹងមួយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដែលកថាខ័ណ្ឌទី៤ នៃសេចក្តីជូនដំណឹងនេះ កំណត់ថា ៖

*"ដោយពិនិត្យឃើញថា ភាគីនៃវិវាទការងារនេះមិនមានសិទ្ធិធ្វើកូដកម្ម ក្នុងកំឡុងពេលនៃដំណើរការរបស់អាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចធ្វើការដោះស្រាយ ឬក៏ចេញសេចក្តីបង្គាប់លើវិវាទការងាររួមនេះបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចដោះស្រាយវិវាទការងាររួមនេះម្តងទៀតបាន នៅពេលណាដែលសហជីពកម្មករនិយោជិតទាំងអស់ឈប់ធ្វើកូដកម្ម "*។

ដូចគ្នាដែរ នៅក្នុងសំណុំរឿងលេខ ១៨/០៤-សណ្ឋាគារ (កាំបូឌីយ៉ាណា, រ៉ាហ្វែល ឡឺរ៉ូយ៉ាល់, រ៉ាហ្វល ព្រែន ឌិ អង្គរ,សាន់វ៉េ, អ៊ិនធើខនធីណេនថល និង សូហ្វីតែល អង្គរ) ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទីពីរ ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ២០០៤ ត្រង់ចំណុចទី៩ និងទី១១ នៃសេចក្តីបញ្ជានេះចែងដូចខាងក្រោម ៖

*"ចំណុចទី៩- ចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ តទៅ កម្មករនិយោជិតទាំងអស់ត្រូវបញ្ឈប់កូដកម្ម បាតុកម្ម ឬ ការរំខានណាមួយ នៅក្នុងបរិវេណសណ្ឋាគារនានា ដែលជាភាគីនៃវិវាទនេះ "* ។

*"ចំណុចទី ១១ - ក្រុមប្រឹក្សាអាជ្ញាកណ្តាលរក្សាសិទ្ធិក្នុងការបញ្ចប់ដំណើរការអាជ្ញាកណ្តាល ករណីដែលភាគីណាមួយបំពានប្រការណាមួយនៃសេចក្តីបញ្ជានេះ "* ។

នៅក្នុងសំណុំរឿងលេខ ៧៧/០៦-ប្រ៊្វង់កូ ទីតធីង ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទី២ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៥ ហើយបានចែងនៅក្នុងចំណុចទី៤ថា នៅក្នុងករណីដែលភាគីកម្មករនិយោជិតបន្តធ្វើកូដកម្ម ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនដំណើរការដោះស្រាយវិវាទការងាររួមនេះទេ ។

នៅក្នុងសំណុំរឿងលេខ ១១០/១១-ស៊ីម៉ាណូ និងសំណុំរឿងលេខ ១៧/១៣-អ៊ិនធើណាស្យូណាល់ ហ្វេសិនរ៉ូយ៉ាល់ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានចេញសេចក្តីបង្គាប់មិនបន្តដំណើរការអាជ្ញាកណ្តាល ដោយមូលហេតុ កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មក្នុងកំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែរ ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងខាងលើដែរ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកោះហៅភាគីទាំងពីរមកបំភ្លឺលើករណីកូដកម្មនេះនៅថ្ងៃ ទី២៩ ខែឧសភា ឆ្នាំ ២០១៣ ។ ប៉ុន្តែ ភាគីកម្មករនិយោជិតមិនមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ហើយតាមរយៈការលើកឡើងរបស់ភាគីនិយោជក កូដករនៅតែបន្តធ្វើកូដកម្ម ដោយមិនគោរពតាមសេចក្តីបញ្ជា របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៣ ឡើយ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចមិនបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះទេ ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

- មិនបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ១០៤/១៣-សាប្រីណា។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា ៖ ---------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **ហួន ជុនឌី**

ហត្ថលេខា ៖ ---------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ---------------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL